ចលនានិស្សិត
ដើម្បីលទ្ធិប្រជាធិបតេយ្យ

បេសកកម្ម ២០២១
ឯករាជ្យជាតិ និង សន្តិភាពផ្ទៃក្នុង
ទឹកដីភូមិផែន និង អន្តោប្រវេសន៍
សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ
យុត្តិធម៌សង្គម និង នីតិរដ្ឋស្អាតស្អំ

ក្រុមប្រឹក្សាភិបាល
លោក ម៉ែន ណាត ប្រធាន
លោក គឹម សុខ អនុប្រធាន

គណៈកម្មាធិការប្រតិបត្តិ
លោក ទូច វិបុល ប្រធាន
លោក អៀប សេង អនុប្រធាន

**STUDENT MOVEMENT
FOR DEMOCRACY
(SMD)**

Mission 2021
National Independence and Peace
Sovereignty and Immigration
Human Rights and Democracy
Social Justice and Rule of law

Leadership
Men Nath, Chairman of BoD
Kim Sok, Vice Chairman of BoD
Vibol Touch, President
Eab Seng, Vice President

2402 24th St SE
Washington, DC 20020
t: 743-999-2110
e: smd2khmer@gmail.com
@: cambodiademocracy.org

លេខ៖ ០០៧/២០២១ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

សូមគោរពជូន
ឯកឧត្តម អេនថូនី ជេ. ប្លីនខេន (Antony J. Blinken)
រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក

ឯកឧត្តមរដ្ឋមន្ត្រី ជាទីគោរពរាប់អាន

ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលជាអង្គការបណ្តុំបញ្ញវន្តខ្មែរជុំវិញពិភពលោក និងមានមូលដ្ឋាននៅរដ្ឋធានីវ៉ាស៊ីនតុនឌីស៊ី នៃសហរដ្ឋអាមេរិក ធ្វើកិច្ចការតស៊ូមតិលើគោលនយោបាយ និងទំនាក់ទំនងអន្តរជាតិ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ យើងខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការធ្លាក់ចុះនៃវិស័យសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ានជាក់ស្តែង ចរន្តនៃការវិលត្រឡប់មកវិញដ៏សម្បើម នៃអំណាចក្រុមយោធានិយមនៅព្រះរាជាណាចក្រកម្ពុជា, នៅព្រះរាជាណាចក្រថៃ និងនៅប្រទេសភូមាចុងក្រោយនេះ ។

នយោបាយរដ្ឋប្រហារអចិន្ត្រៃយ៍ដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅប្រទេសកម្ពុជា និងអំណាចក្បត់ឆន្ទៈរាស្ត្រនៅថៃ នៃលោក **ប្រាយុទ្ធ ចាន់អូចា** ដែលមានរបៀបផែនស្រដៀងគ្នានឹងកម្ពុជាដែរ ព្រមទាំងរដ្ឋប្រហារយោធានៅប្រទេសភូមា ដោយឧត្តមសេនីយ៍ **មិន អុងឡាំង** ថ្មីៗនេះ ស្តែងអំពីទំនោរចរន្តនៃការពង្រីកកម្លាំងកុម្មុយនិស្តនៅអាស៊ាន ជានិន្នាការបញ្ច្រាសនឹងបំណងប្រាថ្នារបស់ពលរដ្ឋនៃប្រទេសនីមួយៗ ដែលកំពុងបង្ហាញការតវ៉ាប្រឆាំងយ៉ាងខ្លាំងបំផុត ដើម្បីការផ្លាស់ប្តូរទៅកាន់ប្រជាធិបតេយ្យ ។ អំណាចបំពានឆន្ទៈរាស្ត្រទាំងអស់នេះ រំលោភទាំងស្រុងលើលក្ខន្តិកៈនៃសមាគមអាស៊ាន, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ, ធម្មនុញ្ញអង្គការសហប្រជាជាតិ, និងសណ្តាប់ធ្នាប់អន្តរជាតិសេរីនិយមបើកចំហរ និងឈរលើគោលការណ៍នីតិរដ្ឋ ដែលសហរដ្ឋអាមេរិកជាអ្នកផ្តួចផ្តើមបង្កើតឡើង នៅក្រោយសង្គ្រាមលោកលើកទី២ ។

នៅចំពោះមុខការរីករាលដាលនៃអំណាចផ្តាច់ការក្នុងតំបន់អាស៊ាន យើងខ្ញុំមើលឃើញថា គឺជាការចាំបាច់ខ្លាំងណាស់ ដែលត្រូវតែឲ្យប្រទេសលោកសេរីប្រជាធិបតេយ្យ ជាពិសេសសហរដ្ឋអាមេរិកគិតពិចារណាឡើងវិញនូវតួនាទីអាទិភាពរបស់ខ្លួន ជាថ្មីជាបន្ទាន់ ក្នុងកិច្ចអន្តរាគមន៍ តទល់នឹងពួកមេដឹកនាំយោធាផ្តាច់ការទាំងនេះ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យក្នុងន័យសកល ។ ពេលនេះគួរតែជាពេលវេលាសម្រាប់រដ្ឋបាលប្រធានាធិបតី **ចូ បៃដិន** ដើរតួនាទីកាន់តែស្វាហាប់ក្នុងការធ្វើកិច្ចសហការជាមួយសម្ព័ន្ធមិត្ត និងដៃគូនានា ដើម្បីពន្លឿនកិច្ចអន្តរាគមន៍ និងបង្កើនទម្ងន់សម្ពាធឲ្យចំស្ថានការណ៍ សង្កត់ធ្ងន់លើអំណាចពួកយោធាផ្តាច់ការ តាមតួនាទីជាអន្តរជាតិរបស់សហរដ្ឋអាមេរិក ។

ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ យល់ឃើញថា គឺជាករណីដែលត្រូវធ្វើបានការអន្តរាគមន៍ជាក់ស្តែង និងជាបន្ទាន់ ឆ្លើយតបនឹងទង្វើប្លន់អំណាចរបស់ពួកយោធាភូមា ដែលប្រើពិធីចាប់ឃុំខ្លួនលោកស្រី **អុង សាន ស៊ូជី** និងមន្ត្រីជាន់ខ្ពស់ប្រមាណជិត២០០នាក់ នៃគណបក្សសម្ព័ន្ធជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ហើយនិងអំពើហិង្សាសម្លាប់ជីវិតបាតុករយ៉ាងតិច៣នាក់ និងបានបង្កឲ្យរបួសលើសពី៣០នាក់ ព្រមទាំងការប្លន់អំណាចនៅថៃ និងនៅកម្ពុជា ដោយការជាន់ឈ្លីឆន្ទៈប្រជាពលរដ្ឋ ។ នៅកម្ពុជា នយោបាយអំណាចរដ្ឋប្រហារអចិន្ត្រៃយ៍របស់លោក **ហ៊ុន សែន** ជំណាក់កាលចុងក្រោយនេះ ប្រព្រឹត្តឡើងដោយការចាប់ឃុំខ្លួនមេដឹកនាំគណបក្សសង្គ្រោះជាតិ លោក **កឹម សុខា** ការរំលាយគណបក្សប្រឆាំងនេះ ការបិទសិទ្ធិនយោបាយមន្ត្រីជាន់ខ្ពស់នៃគណបក្សនេះជាង១១៨នាក់ ការប្លន់យកអាសនៈក្រុមប្រឹក្សាឃុំ/សង្កាត់/តំណាងរាស្ត្រជាង៥០០០កន្លែង និងការធ្វើទុក្ខបុកម្នេញសកម្មជនប្រជាធិបតេយ្យ និងប្រជាពលរដ្ឋ ហើយនៅតែរុសបន្លាយស្ថានភាពសម្រាប់ប្រជាធិបតេយ្យកម្ពុជាជាប់គាំងទៅជាងបីឆ្នាំមកហើយ ដោយគ្មានពន្លឺដំណោះស្រាយ ។

វាគឺជាមេរៀនដ៏អាក្រក់ណាស់ នៅពេលមានការរំលាយគណបក្សសង្គ្រោះជាតិកម្ពុជា ប៉ុន្តែរដ្ឋាភិបាលលោក **ហ៊ុន សែន** ដែលជាមេក្លោងនៃអំពើរំលោភរដ្ឋធម្មនុញ្ញ និងក្បត់ឆន្ទៈពលរដ្ឋខ្មែរ បែរជាប្រឈមនឹងប្រតិកម្មសម្ពាធស្រាលពេក និងយឺតយ៉ាវ ពីសហគមន៍អន្តរជាតិ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិនោះ ។ មេរៀននេះក៏បានបង្រៀនពួកយោធាថៃ ឲ្យគម្លើន មិនញញើតនឹងការរំលាយគណបក្សប្រឆាំងនៅប្រទេសថៃដែរ ។ ហេតុដូច្នេះ ចំណាត់ការយឺតយ៉ាវលើរបបយោធាភូមា ក៏អាចនឹងក្លាយជាគំរូលើកទឹកចិត្តពួកផ្តាច់ការនៅប្រទេសផ្សេងៗទៀត ឲ្យហ៊ានពង្រីកឥទ្ធិពលអំណាចយោធារបស់ខ្លួន និងរឹតតែធ្វើឲ្យស្ថានភាពអាស៊ានឲ្យឧបទ្រពដ៏រាលដាល ។

ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ យល់ឃើញថា ការបណ្តោយឲ្យពួកយោធាមួយថ្ងៃ ពួកគេអាចពង្រឹងអំណាចបានរឹងមាំមួយកម្រិត, បើបណ្តោយឲ្យពួកយោធាមួយឆ្នាំ ពួកគេអាចសម្រេចឃើញក្រឡាបន្តប្លន់អំណាចបានយូរឆ្នាំ, ប៉ុន្តែបើបណ្តោយឲ្យពួកយោធាដល់ច្រើនឆ្នាំ មេដឹកនាំយោធាអាចរកឃើញផ្លូវក្តោបក្តាប់ប្រទេសនោះច្រើនអាណត្តិឬមួយជីវិត ដោយល្បិចល្បែងរដ្ឋប្រហារអចិន្ត្រៃយ៍ ដូចឃើញនៅកម្ពុជា ដែលលោក **ហ៊ុន សែន** ចាត់ទុកប្រទេសកម្ពុជា ជាទ្រព្យសម្បត្តិកម្មសិទ្ធិរបស់គ្រួសារខ្លួន ហើយប្រជាពលរដ្ឋខ្មែរក្លាយជាឧបករណ៍រស់សម្រាប់តែកំដរអំណាច និងភាពស្តុកស្តម្ភនៃគ្រួសាររបស់គាត់ប៉ុណ្ណោះ ។ សហរដ្ឋអាមេរិកគួរតែពិចារណាអំពីស្ថានភាពនេះ ហើយយើងខ្ញុំជឿជាក់ថា សហរដ្ឋអាមេរិកអាចជួយពលរដ្ឋរងគ្រោះក្រោមអំណាចជនផ្តាច់ការទាំងឡាយ ឲ្យរួចផុតពីចំណងរំលោភបំពានគ្រប់ទម្រង់បាន ។

ប្រធានប្រតិបត្តិ

ទូច វិបុល